**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
# ស្តីពី
# វឌ្ឍនភាពនៃការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជន ឱ្យបានជ្រាបថា ដើម្បីបន្តសម្របសម្រួលដោះស្រាយបញ្ចប់វិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍ ដូចដែលក្រសួងបានខិតខំនាពេលកន្លងមក និងស្របតាមស្មារតីនៃកិច្ចសន្យា ក៏ដូចជាសំណូមពររបស់អតីតបុគ្គលិកក្រុមហ៊ុន ណាហ្គាវើលដ៍ ដែលបានអះអាងជាមួយក្រសួងថានឹងធ្វើជាតំណាងរបស់អតីតបុគ្គលិក និងបុគ្គលិកក្រុមហ៊ុន ណាហ្គាវើលដ៍ ក្នុងការដោះស្រាយបញ្ចប់វិវាទការងាររួមជាមួយក្រុមហ៊ុន ណាហ្គាវើលដ៍ ក្រសួងបានអញ្ជើញតំណាងភាគីកម្មករនិយោជិត និងតំណាងភាគីនិយោជកមកបន្តប្រជុំដោះស្រាយវិវាទនៅទីស្តីការក្រសួង នៅថ្ងៃពុធ ទី១៦ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ២រសៀល។

ជាក់ស្តែង នៅរសៀលថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ នេះ តំណាងភាគីនិយោជកបានមកចូលរួមប្រជុំតាមការអញ្ជើញរបស់ក្រសួង ចំណែកតំណាងភាគីកម្មករនិយោជិតមិនបានមកចូលរួមប្រជុំតាមការអញ្ជើញរបស់ក្រសួងឡើយ។

ក្រសួងមានការសោកស្តាយដែលកិច្ចប្រជុំនេះមិនអាចដំណើរការបាន។ ជាថ្មីម្តងទៀត ក្រសួងក៏សូមអំពាវនាវដល់តំណាងភាគីកម្មករនិយោជិត មេត្តាចូលរួមប្រជុំតាមការអញ្ជើញរបស់ក្រសួង ដើម្បីដោះស្រាយបញ្ចប់ករណីវិវាទរួមនេះឱ្យបានឆាប់ស្របតាមនីតិវិធីច្បាប់ និងតាមការសន្យារបស់ខ្លួន នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ១៤:៣០នាទីរសៀល នៅទីស្តីការក្រសួង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជ្រាបតាមការគួរ។

ថ្ងៃពុធ ១៤កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ:(០២៣)៨៨ ២៧ ៦៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**គណៈកម្មការសម្រាប់ដោះស្រាយបញ្ហា**
**ក្ងដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា**
**អគ្គលេខាធិការដ្ឋាន**
លេខ ១០៩ អ.គ.ក.ប.

ថ្ងៃពុធ ១៤កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ មីនា ឆ្នាំ២០២២

# លិខិតអញ្ជើញ

**ឯកឧត្តមអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មការ**
**សម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា**

**សូមអញ្ជើញ** : **តំណាងក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត**

**ដើម្បីចូលរួម** : ប្រជុំសម្របសម្រួល ដោះស្រាយករណីវិវាទការងារ នៅក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត

**កាលបរិច្ឆេទ** : ថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ០២:៣០នាទីរសៀល

**ទីកន្លែង** : បន្ទប់ប្រជុំ B នៃទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**សម្លៀកបំពាក់** : សមរម្យ

**អគ្គលេខាធិការ**

តេស-រុក្ខាផល

**សូមទំនាក់ទំនង:**
- 012 911 388
- 077 778 209

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
គណៈកម្មការសម្រាប់ដោះស្រាយបញ្ហា
ករូជកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា
អគ្គលេខាធិការដ្ឋាន
លេខ ១០៩ អ.គ.ក.ប.

ថ្ងៃ ព្រហ ១៤កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ មីនា ឆ្នាំ២០២២

# លិខិតអញ្ជើញ

ឯកឧត្តមអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មការ
សម្រាប់ដោះស្រាយបញ្ហាករូជកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា

**សូមអញ្ជើញ** : **តំណាងអតីតបុគ្គលិកក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត**

**ដើម្បីចូលរួម** : ប្រជុំសម្របសម្រួល ដោះស្រាយករណីវិវាទការងារ នៅក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត ស្របតាមស្មារតីលិខិត សំណូមពររបស់តំណាងកម្មករនិយោជិត មកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២

**កាលបរិច្ឆេទ** : ថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ០២:៣០នាទីរសៀល

**ទីកន្លែង** : បន្ទប់ប្រជុំ B នៃទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**សម្លៀកបំពាក់** : សមរម្យ

អគ្គលេខាធិការ

ឆេង_វុទ្ធាផល

**សូមទំនាក់ទំនង**:
- 012 911 388
- 077 778 209